86/6

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សំណុំរឿងរដ្ឋប្បវេណី**
**លេខ ៖ ២៨៩**
**ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១**
**សាលដីកា**
**លេខ៖ ៥១៧ "ក"**
**ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣**

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣។

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

១-ឯកឧត្ដម [redacted] ជាប្រធាន
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោកស្រី ជាចៅក្រម

**ក្រឡាបញ្ជី**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទ៖**អ្នកស្រី [redacted] (ម្ចាស់បណ្ដឹងសាទុក្ខ) អាយុ ៥៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ អូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

**មេធាវី ៖** លោក [redacted] តំណាងដោយអាណត្តិ

**ចុងចម្លើយ៖**អ្នកស្រី [redacted] សុឃីម (ម្ចាស់បណ្ដឹងសាទុក្ខ) អាយុ ៣២ឆ្នាំ ជាតិខ្មែរ មានទីលំនៅ

១៩៨



Scanned with CamScanner

សព្វថ្ងៃភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

**មេធាវី : លោក [redacted] តំណាងដោយអាណត្តិ**

**<u>កម្មវត្ថុបណ្តឹង</u> : សុំបញ្ជាក់ទទួលស្គាល់សិទ្ធិកាន់កាប់ និង ប្រគល់អចលនទ្រព្យ។**

## <u>អំពីអង្គហេតុ និង ចំណុចវិវាទ:</u>

### ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:</u>

កាលពីឆ្នាំ ២០០១ ឈ្មោះ [redacted] ថាច បានទិញផ្ទះ និង ដីសម្រាប់សង់ផ្ទះល្វែងពីឈ្មោះ [redacted] អេងណៃ និង ប្តីឈ្មោះ [redacted] ហួរ ទំហំ ៦៨ម² ដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរលេខ ០៣ គរជ/លអប ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ក្នុងតម្លៃ ២៧០.០០០បាត(ពីររយចិតសិបពាន់បាត) លុះដល់ឆ្នាំ ២០០២ ឈ្មោះ [redacted] ថា បានធ្វើការជួសជុល និង ពង្រីកបន្ថែមលើចំណែកដីដែលនៅសល់ចំនួនមួយល្វែងទៀតបានជាពីរល្វែង។ ក្នុងឆ្នាំ ២០០៥ ឈ្មោះ [redacted] គីមហាង ត្រូវជាកូនរបស់ឈ្មោះ [redacted] ថាច បានទទួលមរណៈភាពដោយគ្រោះថ្នាក់ចរាចរ ហើយក្រោយមកស្រាប់តែឈ្មោះ [redacted] សុឃីម ត្រូវជាកូនប្រសារបានបង្ខំអោយធ្វើបណ្តាំមរតកទៅអោយចៅ តែឈ្មោះ [redacted] ថាច ពុំយល់ព្រម ហើយឈ្មោះ [redacted] សុឃីម បានចាក់សោរមិនអោយឈ្មោះ [redacted] ថាច ចូលទៅរស់នៅ ទើបទំនាស់កើតមានឡើង។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៤ "ក" ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ សំរេច:**

១-បញ្ជាក់ទទួលស្គាល់សិទ្ធិកាន់កាប់អាស្រ័យផលអចលនវត្ថុ នៃដី និង ផ្ទះល្វែងទំហំ ៦៨ម² ដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរលេខ ០៣ គរជ.លអប ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជារបស់ឈ្មោះ [redacted] ថាច ប៉ុន្តែក្នុងករណីរដ្ឋត្រូវការ ត្រូវប្រគល់ជូនរដ្ឋវិញ។

២-បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] សុឃីម ប្រគល់អចលនវត្ថុ នៃដី និង ផ្ទះល្វែងទំហំ ៦៨ម² ដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរលេខ ០៣ គរជ/លអប ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ



Scanned with CamScanner

ខេត្តបន្ទាយមានជ័យ អោយទៅឈ្មោះ [redacted] ថាច ដើម្បីគ្រប់គ្រងកាន់កាប់អាស្រ័យផលតាមច្បាប់ ។

៣-បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] សុឃីម ចុះចេញពីដី និង ផ្ទះល្វែងទំហំ ៦៨ម² ដែលមាននៅក្នុងប័ណ្ណលក់ផ្ទះល្វែងទីផ្សារដើមគរលេខ ០៣ គរជ/ល អ ប ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៨៣ ចេញដោយប្រធានគណៈកម្មការរៀបចំផ្សារ ដែលស្ថិតនៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

៤-បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] សុឃីម សងប្រាក់ជម្ងឺចិត្ត និង ការបង់ខាតពេលវេលាចំនួន ៥.០០០.០០០រៀល( ប្រាំលានរៀល) អោយទៅដើមចោទឈ្មោះ [redacted] ថាច ។

៥-បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] សុឃីម ទទួលបន្ទុកលើប្រាក់ពន្ធលើពាក្យបណ្ដឹង និង ប្រាក់ប្រដាប់ក្ដីផ្សេងៗទាំងអស់ ។

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] សុឃីម ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ០៦ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ គ្រប់ចំណុច នៃសេចក្ដីសំរេចទាំងមូល ។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៩ ក្រ V.អ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ របស់សាលាឧទ្ធរណ៍សំរេច :**

១-លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ០៤(ក) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២-បែងចែកដី និង ផ្ទះល្វែងទំហំ ៦៨ម² នៅទីផ្សារដើមគរភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាពីរតាមបណ្ដោយដី :

ក/ប្រគល់សិទ្ធិកាន់កាប់អាស្រ័យផលលើដី និង ផ្ទះល្វែងទទឹង ៣ម ៤០ អោយទៅឈ្មោះ [redacted] សុឃីម ដើម្បីគ្រប់គ្រងទុកអោយកូនទាំងពីរឈ្មោះ [redacted] វុនឈាង និង [redacted] វុនឈិង ។

ខ/ប្រគល់សិទ្ធិកាន់កាប់អាស្រ័យផលលើដី និង ផ្ទះល្វែងទទឹង ៣ម ៤០ អោយទៅឈ្មោះ [redacted] ថាច ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

៤-សាលដីកានេះបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និង ប្រកាសជាសាធារណៈ បើកផ្លូវប្ដឹងសាទុក្ខរយៈពេល ១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលដីកានេះ ។



Scanned with CamScanner

*សាលដីកានេះត្រូវបានលោកមេធាវី [redacted] តំណាងដោយអាណត្តិអោយឈ្មោះ [redacted] ថាច ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ ៣០៧ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ ត្រង់ចំណុច នៃសេចក្ដីសំរេចទាំងមូល ។*

*សាលដីកានេះត្រូវបានឈ្មោះ [redacted] សុឃីម ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ ៣៣៣ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ត្រង់ចំណុច នៃសេចក្ដីសំរេចទាំងមូល ។*

**ខ-<u>អំពីសេចក្ដីថ្លែងការណ៍របស់គូភាគី</u>:**

**ឈ្មោះ** [redacted] សុឃីម ធ្វើសេចក្ដីថ្លែងការណ៍ថា : ខ្លួនចង់បានផ្ទះនេះទុកអោយកូន ព្រោះដី និង ផ្ទះនេះជាទ្រព្យរួមរបស់ប្ដីប្រពន្ធខ្លួន។ ពេលទិញផ្ទះនេះបានដាក់ឈ្មោះប្ដីប្រពន្ធខ្លួន តែត្រូវម្ដាយក្មេកខ្លួនទារយកទៅទុក រហូតប្ដីខ្លួនស្លាប់ក៏នៅតែមិនព្រមអោយ។ ផ្ទះនេះទំហំ ៤ម ក្រោយមកខ្លួនខ្ចីលុយបងប្រុសខ្លួនយកមកធ្វើពង្រីកផ្ទះបានជាង ៦ម ។

**ឈ្មោះ** [redacted] ថាច ធ្វើសេចក្ដីថ្លែងការណ៍ថា : ពេលកូនខ្លួនទើបរៀបការ ខ្លួនក៏បានទិញផ្ទះនេះអោយកូននៅបណ្ដោះអាសន្ន បើកូនប្រសារដឹងគុណខ្លួនៗអោយ តែបើមិនដឹងគុណទេ ខ្លួនមិនអោយទេ។ បច្ចុប្បន្នកូនប្រុសខ្លួនស្លាប់ហើយៗ នាង ឡា សុឃីម ក៏មានប្ដីថ្មីទៀតដែរ។

**សំណូមពរ :** សុំទាមទារគ្រប់គ្រងផ្ទះ និង ដីរបស់ខ្លួន។

**លោក** [redacted] មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] សុឃីម ធ្វើសេចក្ដីថ្លែងការណ៍ថា : សាលក្រមសាលដំបូងមានការខុសឆ្គង ឯសាលដីកាសាលាឧទ្ធរណ៍បានសំរេចបែងចែកជាពីរចំណែកនេះកូនក្ដីខ្លួនព្រម តែដោយឈ្មោះ [redacted] ថាច ប្ដឹងសាទុក្ខ ទើបកូនក្ដីខ្លួនប្ដឹងសាទុក្ខដែរ ។ ក្រោយរៀបការបានទិញផ្ទះឈើ ក្រោយមករុះរើ និង ពង្រីកបានជាពីរល្វែង ១ល្វែង ទំហំ ៣,៤០ម ។ នៅឆ្នាំ ២០០៥ កូនប្រុសគាត់ស្លាប់ ទើបគាត់ប្ដឹងទាមទារយកផ្ទះទាំងមូល។ បើតុលាការកំពូលសំរេចបែងចែកជាពីរស្មើ គឺកូនក្ដីខ្លួនទទួលយកបាន តែបើដើមចោទមិនព្រម កូនក្ដីខ្លួនក៏សំណូមពរសុំគ្រប់គ្រងផ្ទះទាំងមូលដែរ ព្រោះកូនក្ដីខ្លួនរស់នៅផ្ទះនេះ ១២ឆ្នាំ ហើយ ។

**លោក** [redacted] ធារី មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] ថាច ធ្វើសេចក្ដីថ្លែងការណ៍ថា : ក្រោយកូនរៀបការហើយ កូនក្ដីខ្លួនបានទិញដី និង ផ្ទះពីឈ្មោះ [redacted] អេងណៃ អោយកូននៅបណ្ដោះអាសន្ន នៅឆ្នាំ ២០០២ ដើមចោទបានសុំទៅអាជ្ញាធរសាងសង់ផ្ទះថ្ម និង មានលិខិតប្រគល់ប្រាក់ថ្លៃសាងសង់អោយជាង ៩៥.០០០បាត។ ក្រោយឆ្នាំ ២០០៥ ក្រោយកូនគាត់ស្លាប់ទៅ ឈ្មោះ [redacted] សុឃីម បានមកបង្ខំអោយដើមចោទប្រគល់ផ្ទះជាមរតកអោយកូនៗខ្លួន ពេលដើមចោទមិនព្រម ត្រូវចុងចម្លើយដេញគាត់អោយចេញពីផ្ទះ។



Scanned with CamScanner

ចៅសង្កាត់បានចេញលិខិតអោយ [redacted] សុឃីម ប្រគល់ផ្ទះ និង សោរអោយដើមចោទ។ ការសំរេចបែងចែកផ្ទះ និង ដីជាពីរចំណែក គឺជាការខុសឆ្គង ព្រោះជាកម្មសិទ្ធិរបស់កូនក្តីខ្លួន ត្រូវទុកសិទ្ធិអោយកូនក្តីខ្លួនជាអ្នកសំរេចថាអោយ រឺមិនអោយ ។ ខ្លឹមសារនៃលិខិតប្រគល់ប្រាក់ គឺបានបញ្ជាក់ច្បាស់ហើយថា ជាការទិញដី និងផ្ទះមែន។ ចំណែកចុងចម្លើយពុំមានភស្តុតាងបញ្ជាក់អំពីការចេញប្រាក់ចូលទិញផ្ទះ និង ដីនេះទេ។

**សំណូមពរ :** សុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិអោយគូភាគី
-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣០៧ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ របស់លោក [redacted] ផារីមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] ថាច និង បណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ឈ្មោះ [redacted] សុឃីម ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចបែងចែកដី និង ផ្ទះល្វែងទំហំ ៦៨ម² នៅផ្សារដើមគរ ភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាពីរចំណែកនោះ គឺពុំមានមូលដ្ឋានច្បាស់លាស់នៅឡើយទេ ពីព្រោះថា ចុងចម្លើយសំអាងតែទៅលើកិច្ចសន្យាខ្ចីប្រាក់ពីបងរបស់ខ្លួននៅឆ្នាំ ១៩៩៩ ថាជាប្រាក់យកមកទិញផ្ទះល្វែងទំនាស់នេះ សំអាងនេះមិនគ្រប់គ្រាន់ដើម្បីបញ្ជាក់បានថា ប្រាក់ទិញផ្ទះល្វែងទំនាស់នេះជាប្រាក់របស់ចុងចម្លើយ ដែលជាហេតុអាចអោយចុងចម្លើយទទួលបានសិទ្ធិលើផ្ទះល្វែងនេះទាំងស្រុង ឬមួយផ្នែកនោះទេ ហើយម្យ៉ាងវិញទៀតឯកសារដើមនៃលិខិតទិញលក់ផ្ទះល្វែងពីម្ចាស់ដើមឈ្មោះ [redacted] អេងណៃទៅអោយដើមចោទ និង ឯកសារដើមនៃលិខិតប្រគល់ប្រាក់ពីដើមចោទទៅអោយឈ្មោះ [redacted] អេងណៃ ក៏ពុំបានដាក់ជូនតុលាការ ដើម្បីយកមកធ្វើជាមូលដ្ឋានសំរេចសេចក្តីអោយបានច្បាស់លាស់ដែរ។



Scanned with CamScanner

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២៩ ក្រVអ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ ពុំត្រឹមត្រូវតាមគតិច្បាប់ទេ។

## ហេតុដូចនេះ

## វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣០៧ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] ថាច និង បណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១១ របស់ឈ្មោះ [redacted] សុឃីម ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ២៩ ក្រVអ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ២៨៩ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសាជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់គូភាគី។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ចៅក្រម |
| លោក | | ក្រឡាបញ្ជី |

---

បានផ្តិតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣

ប្រធាន

[redacted]



Scanned with CamScanner